ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០២ សសរ

សេចក្ដីសម្រេច

ស្ដីពី

ការលុបចោលប័ណ្ណបើកបរប្រភេទ ក១

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកត/០០១៥/០០១ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការដោះស្រាយសំណូមពរដ៏ទទូចនិងសេចក្ដីត្រូវការចាំបាច់របស់ប្រជាជន

សម្រេច

ប្រការ ១.- លុបចោលប័ណ្ណបើកបរប្រភេទ ក១ មានន័យថា អ្នកបើកបរទោចក្រយានយន្តដែលមានកម្លាំងចាប់ពី ១២៥ CC ចុះក្រោម មិនចាំបាច់មានប័ណ្ណបើកបរទៀតទេ ។

ប្រការ ២.- ប្រគល់ភារកិច្ចជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដឹកនាំការងាររៀបចំធ្វើវិសោធនកម្មជាបន្ទាន់ លើបទ-បញ្ញត្តិច្បាប់ដែលមានការពាក់ព័ន្ធសម្រាប់ដាក់ឆ្លងគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ដើម្បីបញ្ជូនទៅស្ថាប័ននីតិបញ្ញត្តិពិនិត្យ និងផ្តល់ការអនុម័តជាកិច្ចការប្រញាប់ ។

ប្រការ ៣.- ក្រសួងមហាផ្ទៃ និងក្រសួងសាធារណការនិងដឹកជញ្ជូនត្រូវចាត់ចែងបង្កើនយុទ្ធនាការផ្សព្វផ្សាយ និងបង្រៀនច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឱ្យបានទូលំទូលាយជូនដល់សាធារណជន ជាពិសេសតាមរយៈស្ថានីយ៍វិទ្យុ ទូរទស្សន៍ និងផ្ទាំងប៉ាណូរូបភាពតាមទីសាធារណៈដើម្បីបង្កើនការយល់ដឹងអំពីច្បាប់ចរាចរណ៍ ក៏ដូចជាលើកស្ទួយការគោរពច្បាប់ចរាចរណ៍ និងលើកកម្ពស់សុវត្ថិភាពរបស់ប្រជាពលរដ្ឋក្នុងការធ្វើចរាចរណ៍ផ្លូវគោក ។

ប្រការ ៤.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល:</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៤*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ*